ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 08 / 2012
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១៥ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៨៦

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត់, លោក ច័ន្ទ តារាស្មី, លោក Dale LYSAK, លោក Vincent DE WILDE D'ESTMAEL, លោក Tarik ABDULHAK, លោក RAYNOR Keith |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក Ferdinand DJAMMEN NZEPA, លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវន, លោក វ៉េន ពៅ, លោក សំ សុគង់, លោកស្រី Beini YE, លោក ហុង គីមសួន, លោកស្រី ម៉ុច សុវណ្ណារី |
| សាក្សី៖ សួង ស៊ីគឿន (TCW-694), ស សៀក (TCW-609) |
| មន្រ្តីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សារបស់សាក្សី សួង ស៊ីគឿន), កញ្ញា Sonia MESSAOUDI, កញ្ញា ជា ស៊ីវហ៊ាង |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៤៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០៤<br>១២.០៣ | ០៩.០៦<br>១២.០៤ |
| ការតាំងសំណួរបន្តចំពោះសាក្សី សួង ស៊ីគឿន TCW-694 | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី | ០៩.០៧<br>១១.២៤ | ១១.២៣<br>១២.០០ |
| ការតាំងសំណួរទៅកាន់សាក្សី ស សៀក TCW-609 | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៣.៣៥<br>១៣.៤៤ | ១៣.៤៤<br>១៦.០០ |
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើ | អង្គជំនុំជម្រះ | ១០.២២ | ១០.២៣ |

| | | | |
|---|---|---|---|
| របស់មេធាវីការពារក្តី អំពីការប្រើប្រាស់ឯកសារ និងការតាំងសំណួរដល់សាក្សី | | | |
| សេចក្តីសម្រេចផ្ទាល់មាត់ លើសំណើរសុំឱ្យអង្គជំនុំជម្រះអនុវត្តនូវសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានចេញពីពេលមុនទាក់ទងនឹងការប្រើប្រាស់ឯកសារ | អង្គជំនុំជម្រះ | ១៥.៣០ | ១៥.៣១ |
| សេចក្តីសម្រេចផ្ទាល់មាត់ទៅលើសំណើរបស់មេធាវីការពារក្តីទាក់ទងនឹងការដកស្រង់ឯកសារសម្រាប់តាំងសំណួរដល់សាក្សី | មេធាវីការពារក្តី នួន ជា | ១៥.៤៦ | ១៥.៤៦ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ អៀង សារី (៩.០៥) និង នួនជា (១២.០៥) តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ (ជនជាប់ចោទ អៀង សារី ស្នើសុំលះបង់សិទ្ធិសម្រាប់រយៈពេលពេញមួយថ្ងៃ ហើយជនជាប់ចោទ នួន ជា ស្នើសុំសម្រាប់ពេលរសៀល) ។

**<u>ការតាំងសំណួរបន្តចំពោះសាក្សី សួង ស៊ីគឿន (TCW-694)</u>**

មេធាវីការពារក្តីជនជាប់ចោទ នួន ជា បន្តនិងបញ្ចប់ការតាំងសំណួរចំពោះសាក្សី។

**<u>ការតាំងសំណួរចំពោះសាក្សី ស សៀក ហៅ ស៊ឹម (TCW-609)</u>**

អង្គជំនុំជម្រះបានចាប់ផ្តើមសួរសំណួរមួយចំនួនដល់សាក្សី ។ បន្ទាប់មក សហព្រះរាជអាជ្ញាចាប់ផ្តើមតាំងសំណួរទៅកាន់សាក្សី។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី អំពីការប្រើប្រាស់ឯកសារ និងការតាំង</u>**

**សំណួរដល់សាក្សី**

មេធាវីការពារក្តី នួន ជា មានបំណងប្រើប្រាស់ឯកសារមួយសម្រាប់ការសួរសំណួរដល់សាក្សី ។ ទោះបីជាឯកសារនេះត្រូវបានយកមកប្រើប្រាស់ដោយសហព្រះរាជអាជ្ញាសម្រាប់ការតាំងសំណួរដល់សាក្សីក៏ដោយ ក៏អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យមេធាវីការពារក្តី នួន ជា លើកយកឯកសារនេះមកប្រើប្រាស់នោះទេ ព្រោះឯកសារនេះមិនមានភាពពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ។

**សេចក្តីសម្រេចផ្ទាល់មាត់ លើសំណើសុំឱ្យអង្គជំនុំជម្រះអនុវត្តនូវសេចក្តីសម្រេចដែលអង្គជំនុំ-ជម្រះបានចេញពីពេលមុនទាក់ទងនឹងការប្រើប្រាស់ឯកសារ**

កាលពីពេលមុន អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ភាគីអាចដកស្រង់នូវខ្លឹមសាររបស់ឯកសារសម្រាប់សួរសំណួរដល់សាក្សីបាន ប្រសិនបើសាក្សីរូបនោះមិនដែលបានស្គាល់នូវឯកសារនោះ ។ មេធាវីការពារក្តី ខៀវ សំផន និង នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះអនុវត្តនូវសេចក្តីសម្រេចនេះចំពោះសហព្រះរាជអាជ្ញាផងដែរ ។ សហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់ខ្សែអាត់សម្លេងនៃការផ្សព្វផ្សាយតាមវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យសម្រាប់សួរសំណួរដល់សាក្សី។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារនេះគឺជាឯកសារដែលមានតែមួយដែលទាក់ទងនឹងរឿងក្តី ហើយសហព្រះរាជអាជ្ញាបានទទួលស្គាល់ថា សាក្សីរូបនេះប្រហែលជាមិនបានដឹងអំពីឯកសារនេះទេ។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើការយោងទៅលើឯកសារនេះសម្រាប់ការតាំងសំណួរដល់សាក្សី ។ ប៉ុន្តែ អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យដាក់ឯកសារនេះនៅលើអេក្រង់កំព្យូទ័រ (computer screen) ឬប្រគល់ឯកសារនេះទៅឱ្យសាក្សីនោះទេ ។

អង្គជំនុំជម្រះបានរំឭកផងដែរថា ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនោះ អាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការតាំងសំណួរ ។ ប៉ុន្តែ ប្បញ្ញត្តិទូទៅនេះអាចអនុវត្តបានទេក្នុងករណីដែលឯកសារនោះមិនមានភាពពាក់ព័ន្ធ ហើយសំណួរដែលសួរនោះមានភាពពាក់ព័ន្ធផងដែរ ។

**សេចក្តីសម្រេចផ្ទាល់មាត់នៅលើសំណើរបស់មេធាវីការពារក្តីទាក់ទងនឹងការដកស្រង់ឯកសារសម្រាប់តាំងសំណួរដល់សាក្សី**

មេធាវីការពារក្តី នួន ជា ស្នើសុំការបញ្ជាក់បន្ថែមពីអង្គជំនុំជម្រះ ថាតើឯកសារណាខ្លះដែលភាគីអាចដកស្រង់សម្រាប់សួរសាក្សី និងស្ថានភាពបែបណាដែលភាគីអាចធ្វើដូច្នេះបាន។ មេធាវីក៏បានស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះផងដែរ ទៅលើសេចក្តីសម្រេចដែលកំណត់ថា "ប្រសិនបើឯកសារនោះបានដាក់នៅចំពោះមុខអង្គ-

ជំនុំជម្រះរួចហើយ និងភាពពាក់ព័ន្ធនៃឯកសារនោះ"។ អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះនៅថ្ងៃស្អែក ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1718 | 3.7 | 00103479-00103672 00754756-00754978 00103372-00103478 | សៀវភៅនិពន្ធដោយ Laurence Picq មានចំណងជើងថា៖ "ឆ្ងាយហួសជើងមេឃ" Book entitled "Beyond the Horizon" Livre écrit par Laurence Picq intituté:"Au Delà Du Ciel" | P | | | |
| E3/40 | 3.9 | 00583604-00583636 00528409-00528410, 00813077-00813103 00096751-00096752, 00078986-00079039 | សួង សីឃឿន Account of SUONG Sikoeun alias Kung alias Thorn Phnom Malai / Suong Sikoeun | P | | 00813077-00813103 | 00078986-00079039 |
| E3/371 | D143 | 00288233-00288239 00290412-00290417 00288240-00288245 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួង ស៊ីគឿន ថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៩ [Surrogate Sheet] Written Record of Interview of witness SUONG Sikoeun by CIJ on 12 March 2009 [Feuille remplacée] Procès verbal d'audition de témoin SUONG Sikoeun par CJI le 12 mars 2009 | P | 00288233 | 00290412 | 00288240 |
| E3/42 | D167 | 00327200-00327211 00327212-00327221 00327222-00327230 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួង ស៊ីគឿន ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ [Surrogate Sheet] Written Record of Interview of witness SUONG Sikoeun by CIJ on 06 May 2009 [Feuille remplacée] Procès verbal d'investigations M. TAN Peng Khun/TAN Jean Pierre | P | 00327200 | 00327212 | 00327222 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/9 | D222/1.15 | 00755579-00755583 00396177-00396757 00639445-00640068 | [លិខិតបញ្ជាក់ការជំនួសឯកសារ] [Partial T.] សៀវភៅនិពន្ធដោយ Philip Short មានចំណងជើងថា៖ "ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ" [Surrogate Sheet] Book by Philip Short entitled "Pol Pot, The History of a Nightmare" [Feuille remplacée] Livre écrit par Philip Short intituté "Pol Pot, Anatomie d'un cauchemar" | P | | 00396547-48 | 00639901 |
| E3/1719 | D199/26.2.80 | 00820658-00820659 00742300-00742301 00386798-00386799 | ទូរលេខ មានចំណងជើងថា ដំណើរទស្សនកិច្ចនៅកម្ពុជា របស់រដ្ឋមន្ត្រីការបរទេសថៃ Telegram entitled "Visit to Cambodia by the Thai minister of foreign affairs" Télégramme intitulé Visite au Cambodge du ministre Thailandais des affaires étrangère | P | 00820658 | 00742300 | 00386798 |
| E3/1720 | D22/185.5 | 00387616-00387617 | Annexe 5: Liste de ministères et des dirigants dan láncien regime | P | | | |
| E3/1435 | D56-Doc.187 | 00595262-00595276 S 00017976-00017990 00597811-00597822 | [លិខិតបញ្ជាក់ការជំនួសឯកសារ] សេចក្តីថ្លែងការណ៍របស់សមាជគណៈអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ តំណាងកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ និង តំណាងក្រសួងមន្ទីរនានារបស់រដ្ឋាភិបាល [Surrogate Sheet] Statement of the Congress of the Standing Committee of the Assembly of the Kampuchean People's Representatives, the Government of DK, the Representatives of the DK National Army and the Representatives of Various Governmental [Feuille remplacée] Statement of the Congress of the Standing Committee of the Assembly of the Kampuchean People's Representatives, the Government of DK, the Representatives of the DK National Army and the Representatives of Various Governmental | P | 00595262, 00595274 | 00017976, 00017988 | 00597811 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1721 | D366/7.1.564 | 00636001-00636007 00078096-00078099 00630981-00630984 | សក្ខីកម្មរបស់មនុស្សផ្សេងៗដែលសាច់ញាតិរបស់គេត្រូវបានសម្លាប់ដោយ ប៉ុល ពត និង អៀង សារី Testimony of Various People Whose Relatives Were Murdered by the Pol Pot-Ieng Sary Clique" Vietnamese Archive Document: 1980 32(N442)/T.8341 Dudocument d'archives Vietnamien « Témoignage de différentes personnes dont les membres de la famille ont été assassinés par la clique de Pol Pot-Ieng Sary » : 1980 32(N442)/T.8341 | P | 00636001, 00636007 | 00078096, 00078099 | 00630981, 00630984 |
| E3/379 | D200/6 | 00294797-00294815 00323321-00323339 00385192-00385212 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SÂ Siek ស សៀក [Surrogate Sheet] Written Record of interview of SÂ Siek ស សៀក [Feuille remplacée] Procès verbal d'audition de témoin SÂ Siek ស សៀក | P | 00294801, 00294802, 00294800 | 00323324-25, 00323326, 00323324 | 00385196, 00385197, 00385195 |
| E3/118 | D262.5 | 00700267-00700288 00166888-00167025 00700256-00700266 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ឧបសម្ព័ន្ធ ០០០០៥៖ លោក ខៀវ សំផន ចេញផ្សាយសេចក្តីថ្លែងការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន [Surrogate Sheet] Annex 00005: Foreign Broadcast Information Service collection of reports for April 1975 [Feuille remplacée] Annexe 00005: KHIEU Samphan fait une déclaration sur la situation actuelle | P | 00700267 | 00166897 | 00700256 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០៥) និង នួន ជា (១២.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា៖

អង្គជំនុំជម្រះសម្រេចថា៖ ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីពេលមុន អាចយក

00843040



មកប្រើធ្វើជាមូលដ្ឋានក្នុងការសួរសំណួរដល់សាក្សី ។ ប៉ុន្តែ ប្បញ្ញត្តិទូទៅនេះអាចអនុវត្តបានតែក្នុងករណីដែលឯកសារនោះមានភាពពាក់ព័ន្ធ ហើយសំណួរដែលសួរនោះមានភាពពាក់ព័ន្ធប៉ុណ្ណោះ។

- បង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ នាំសាក្សី សួង ស៊ីគឿន និង ស សៀក ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២។

<u>កាលបរិច្ឆេទបន្តសវនាការ៖</u>

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បតិ៍ ទ ១៦ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី/ក្រឡាបញ្ជី

ឌុច ឆា[illegible]/ Matteo CRIPPA